ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

អាជ្ញាធរជាតិព្រះវិហារ

# សេចក្តីថ្លែងការណ៍
# ថ្កោលទោសចំពោះកងកម្លាំងប្រដាប់អាវុធរបស់ព្រះរាជាណាចក្រថៃ
# ដែលបានរំលោភបំពានលើអនុសញ្ញាទីក្រុងឡាអេ ឆ្នាំ១៩៥៤
# និងការបំផ្លាញធ្ងន់ធ្ងរដល់បេតិកភណ្ឌពិភពលោក ប្រាសាទព្រះវិហារ

អាជ្ញាធរជាតិព្រះវិហារ សូមធ្វើការថ្កោលទោសយ៉ាងខ្លាំងក្លាបំផុតចំពោះអំពើឈ្លានពានរបស់កងកម្លាំងប្រដាប់អាវុធនៃព្រះរាជាណាចក្រថៃ នាថ្ងៃទី២៤-២៥ ខែកក្កដា ឆ្នាំ២០២៥ ដែលបានធ្វើឱ្យប៉ះពាល់ និងបំផ្លិចបំផ្លាញយ៉ាងធ្ងន់ធ្ងរលើរចនាសម្ព័ន្ធផ្ទាល់របស់បេតិកភណ្ឌពិភពលោកប្រាសាទព្រះវិហារ និងបរិវេណជុំវិញ ដែលជាមរតកវប្បធម៌ប្រវត្តិសាស្ត្រដ៏ថ្លៃថ្លារបស់ប្រជាជនខ្មែរ និងមានតម្លៃលេចធ្លោជាសកលសម្រាប់មនុស្សជាតិ។

ការវាយប្រហារដោយមិនញញើត ជាមួយនឹងការប្រើប្រាស់ការបាញ់ប្លោងកាំភ្លើងធំ និងការទម្លាក់គ្រាប់បែកពីលើអាកាសដោយយន្តហោះ F-16 គឺជាការបំពានយ៉ាងធ្ងន់ធ្ងរនិងមិនអាចទទួលយកបាន មិនគោរពទៅតាមអនុសញ្ញាទីក្រុងឡាអេ ឆ្នាំ១៩៥៤ ស្តីពីកិច្ចការពារសម្បត្តិវប្បធម៌នៅក្នុងព្រឹត្តិការណ៍នៃជម្លោះប្រដាប់អាវុធ ពិធីសារទីពីរ ឆ្នាំ១៩៩៩ នៃអនុសញ្ញាទីក្រុងឡាអេឆ្នាំ ១៩៥៤ ពាក់ព័ន្ធនឹងការពង្រឹកកិច្ចការពារ និងគណនេយ្យភាពលើបេតិកភណ្ឌវប្បធម៌ និងអនុសញ្ញាអង្គការយូណេស្កូឆ្នាំ១៩៧២ ស្តីពីកិច្ចការពារបេតិកភណ្ឌវប្បធម៌ និងធម្មជាតិពិភពលោក ដែលប្រទេសថៃជារដ្ឋសមាជិក។

ជាមួយគ្នានេះ ប្រទេសថៃគឺជារដ្ឋសមាជិកមួយនៃគណៈកម្មាធិការសម្របសម្រួលអន្តរជាតិដើម្បីអភិរក្ស និងលើកតម្លៃប្រាសាទព្រះវិហារ (ICC-Preah Vihear) ដែលបានបង្កើតឡើងដោយសេចក្តីសម្រេចលេខ 195EX/32 របស់គណៈកម្មការប្រតិបត្តិរបស់អង្គការយូណេស្កូ ឆ្នាំ២០១៤ មានប្រទេសចិន និងប្រទេសឥណ្ឌា ជាសហប្រធាន រួមជាមួយប្រទេសជាសមាជិកដ៏ទៃទៀតដូចជា បែលហ្ស៊ិក បារាំង ជប៉ុន សាធារណៈរដ្ឋកូរ៉េ និងសហរដ្ឋអាមេរិច ដែលមានតួនាទីនិងភារកិច្ចចូលរួមចំណែកក្នុងការអភិរក្ស និងលើកតម្លៃបេតិកភណ្ឌពិភពលោកប្រាសាទព្រះវិហារ។ ក្នុងន័យនេះ អាជ្ញាធរជាតិព្រះវិហារ សម្តែងនូវការសោកស្តាយដែលប្រទេសថៃមិនបានបំពេញភារកិច្ចរបស់ខ្លួនស្របតាមច្បាប់និងអនុសញ្ញាអន្តរជាតិនានា ក្នុងនាមជាសមាជិកនៃអង្គការយូណេស្កូ និងគណៈកម្មការបេតិកភណ្ឌពិភពលោក ដើម្បីអភិរក្សនិងលើកតម្លៃប្រាសាទព្រះវិហារ ប៉ុន្តែបានធ្វើសកម្មភាពបំផ្លិចបំផ្លាញយ៉ាងធ្ងន់ធ្ងរដោយផ្ទាល់មកលើសម្បត្តិបេតិកភណ្ឌពិភពលោក ហើយបានបង្ករអោយមានការជន្លៀសប្រជាជនរាប់ពាន់គ្រួសារ និងបណ្តាលឲ្យមានគ្រោះថ្នាក់ដល់ជនស៊ីវិលយ៉ាងច្រើន។

អាជ្ញាធរជាតិព្រះវិហារ សូមថ្កោលទោសយ៉ាងម៉ឺងម៉ាត់ និងទាមទារឱ្យភាគីថៃបញ្ឈប់ជាបន្ទាន់ចំពោះសកម្មភាពបាញ់ផ្លោងនិងទម្លាក់គ្រាប់បែកដោយយន្តហោះមកលើប្រាសាទព្រះវិហារ និងតំបន់ជុំវិញប្រាសាទ រួមទាំងការបង្កគ្រោះថ្នាក់ដល់ប្រជាពលរដ្ឋនៅក្នុងតំបន់ប្រាសាទព្រះវិហារទាំងមូល។

អាជ្ញាធរជាតិព្រះវិហារ សូមបញ្ជាក់ជាថ្មីពីការប្តេជ្ញាចិត្តមិនងាករេក្នុងការការពារ និងអភិរក្សបេតិកភណ្ឌពិភពលោកប្រាសាទព្រះវិហារ ទោះជាកំពុងស្ថិតក្នុងស្ថានភាពទទួលរងការឈ្លានពានប្រដាប់អាវុធពីប្រទេសជិតខាងក៏ដោយ។

ថ្ងៃសៅរ៍ ១កើត ខែស្រាពណ៍ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩

ធ្វើនៅខេត្តព្រះវិហារ ថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០២៥

Unofficial Translation

# Statement
## Condemning of the Armed Forces of the Kingdom of Thailand for violating the 1954 Hague Convention and severely damaging the World Heritage Site of Preah Vihear Temple

The National Authority for Preah Vihear expresses its strongest condemnation of the aggression carried out by the armed forces of the Kingdom of Thailand on July 24-25, 2025. This aggression caused significant damage to the physical structure of the World Heritage Site of Preah Vihear Temple and its surroundings, which are precious historical and cultural heritage of the Cambodian people and hold outstanding universal value for humanity.

The indiscriminate attacks, involving artillery shelling and the dropping of bombs by F-16 fighter jets, represent grave and unacceptable violations of the 1954 Hague Convention for the Protection of Cultural Property in the Event of Armed Conflict, the 1999 Second Protocol to the 1954 Hague Convention aimed at strengthening protection of and accountability for cultural heritage, and the 1972 UNESCO Convention Concerning the Protection of the World Cultural and Natural Heritage, to which Thailand is a State Party.

Thailand is a state member of the International Coordinating Committee for the Conservation and Enhancement of Preah Vihear Temple ( ICC-Preah Vihear ), established by UNESCO Executive Board Decision 195 EX/32 in 2014. This committee includes China and India as co-chairs, along with other member states such as Belgium, France, Japan, the Republic of Korea, and the United States, all of whom have the role and responsibility to contribute to the conservation and enhancement of the Preah Vihear Temple World Heritage Site.

In this regard, the National Authority for Preah Vihear expresses regret that Thailand has not fulfilled its obligations under international laws and conventions as a UNESCO member and as part of the World Heritage Committee. Instead, Thailand has directly engaged in serious destructive actions against this World Heritage property, causing the displacement of thousands of families and significant harm to civilians.

The National Authority for Preah Vihear therefore strongly condemns these actions and demands that the Thai forces immediately cease shelling the Preah Vihear Temple and its surrounding area, including harm to civilians in Preah Vihear Temple area.

The National Authority for Preah Vihear reaffirms its unwavering commitment to the protection and preservation of the World Heritage Site of Preah Vihear Temple, even in the face of armed aggression from neighboring countries.

*Preah Vihear, July 26, 2025*

# ផែនទីបង្ហាញទីតាំងទទួលរងការវាយប្រហារពីសំណាក់កម្លាំងយោធាថៃនៅប្រាសាទព្រះវិហារ (២៤ កក្កដា ២០២៥)

## Map Indicating the Areas of Damage Caused by Shelling Conducted by the Thai Armed Foreces at Preah Vihear Temple (24 July 2025)











2025.07.24 17:25


2025.07.24 18:22


2025.07.24 18:22